ធ៧-០៥-០៥៤ ប្រ.ក

# ប្រកាស
## ស្តីពី
## គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធិអំណាចផ្តល់ឥណទាន

**ប្រការ ១.-**

រាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានស្របតាមគោលនយោបាយឥណទានត្រឹមត្រូវ និងប្រុងប្រយ័ត្នការប្រតិបត្តិជាទូទៅនិងនីតិវិធីក្នុងការផ្តល់ឥណទានដែលត្រូវតែបានអនុម័តនិងពិនិត្យឡើងវិញដោយត្រឹមត្រូវពីគណៈគ្រប់គ្រង និង/ឬ ក្រុមប្រឹក្សាភិបាល។

**ប្រការ ២.-**

រាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបង្កើត ៖

១. គោលនយោបាយ និងនីតិវិធីជាលាយលក្ខណ៍អក្សរសម្រាប់ដាក់ចេញនូវគោលនយោបាយឥណទាននីតិវិធីនិងកំណត់សិទ្ធិអំណាចឱ្យខ្ចីរបស់មន្ត្រីឥណទាន និង/ឬ គណៈកម្មការឥណទាន និងក្រុមប្រឹក្សាភិបាលហើយគោលនយោបាយនិងនីតិវិធីទាំងនោះត្រូវតែបានបញ្ជូនទៅបុគ្គលិកដែលពាក់ព័ន្ធនឹងសកម្មភាពផ្តល់ឥណទាន។

២. សំណុំឯកសារឥណទានរបស់អ្នកសុំខ្ចីទាំងអស់ត្រូវតែមានព័ត៌មានថ្មីៗគ្រប់គ្រាន់ និងអាចជឿទុកចិត្តបាន ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ។

**ប្រការ ៣.-**

គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធិអំណាចឱ្យខ្ចីត្រូវមានការវិភាគឥណទាន ដំណើរការអនុម័តឥណទាន នីតិវិធីពិនិត្យឥណទានឡើងវិញតាមគ្រា កំរិតកំណត់អនុម័តឥណទានរបស់មន្ត្រី និង/ឬ គណៈកម្មការឥណទាន វត្ថុធានា និងព័ត៌មានចាំបាច់ផ្សេងៗទៀត។

**ប្រការ ៤.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៥

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**